00323301

D158/5/2/1

# នៅចំពោះមុខអង្គបុរេជំនុំជម្រះ
# នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (អវតក)

សំណុំរឿងព្រហ្មទណ្ឌលេខ៖ ០០២/១៩-០៩-២០០៧-អវតក/កសចស (អបជ ២២)

ឈ្មោះសំណុំរឿង៖ ខៀវ សំផន

ដាក់តម្កល់ជូនៈ អង្គបុរេជំនុំជម្រះ

កាលបរិច្ឆេទដាក់ឯកសារ៖ ៤ ឧសភា ២០០៩

ភាគីអ្នកតម្កល់៖ ក្រុមមេធាវីការពារក្តី

ភាសា៖ ភាសាដើមជាភាសាបារាំង (បកប្រែជាភាសាខ្មែរ)

ប្រភេទឯកសារដែលស្នើឡើងដោយភាគីដាក់ឯកសារ៖ សាធារណៈ

---

## បណ្តឹងឧទ្ធរណ៍របស់ក្រុមការពារក្តីលោក ខៀវ សំផន ប្រឆាំងនឹង "ដីកាសម្រេចលើសំណើសុំបំពេញកិច្ចស៊ើបសួររបស់សហចៅក្រមស៊ើបអង្កេត" ចុះថ្ងៃទី ០៣ ខែ មេសា ឆ្នាំ ២០០៩

---

**អ្នកដាក់ឯកសារ៖**

**មេធាវីជនត្រូវចោទ ខៀវ សំផន**

មេធាវី ស សូវាន

មេ…

ឯកសារបានចម្លងត្រឹមត្រូវតាមច្បាប់ដើម
CERTIFIED COPY/COPIE CERTIFIÉE CONFORME
ថ្ងៃ ខែ ឆ្នាំ នៃការបញ្ជាក់ (Certified Date/Date de certification): 05/05/2009
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: C.A. Fuy

**ជំនួយការ៖**

លោកស្រី សេង សុជាតា

កញ្ញា Charlotte MOREAU

**អ្នកទទួលឯកសារ៖**

**អង្គបុរេជំនុំជម្រះ**

ចៅក្រម ប្រាក់ គឹមសាន

ចៅក្រម ន័យ ថុល

ចៅក្រម ហួត វុត្ថី

លោកស្រីចៅក្រម Katinka LAHUIS

ចៅក្រម Rowan DOWNING

**ការិយាល័យសហព្រះរាជអាជ្ញា៖**

លោកស្រី ជា លាង

លោក Robert PETIT

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 04/MAY/2009
ម៉ោង (Time/Heure): 16:00
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: C.A. Fuy

# គោរពជូនអង្គបុរេជំនុំជម្រះ

## I. សេចក្តីផ្តើម

១. “ពិតណាស់ សហចៅក្រមស៊ើបអង្កេតត្រូវធានាថា គ្រប់ចំណុចនៃនីតិវិធីដែលកំពុងដំណើរការក្នុងពេលបច្ចុប្បន្ននៅក្នុង អវតក មិនត្រូវបានគេមិនគោរពបានឡើយ” [1] ពិតណាស់ឬ?

២. ប្រការដែលសហចៅក្រមស៊ើបអង្កេតប្រកាសថា ខ្លួនគ្មានសមត្ថកិច្ចក្នុងការបំភ្លឺចំពោះការចោទប្រកាន់អំពីអំពើពុករលួយដែលកើតមានឡើងក្នុងរង្វង់អវតក អស់រយៈពេលជាងពីរឆ្នាំមកហើយនោះ សហចៅក្រមស៊ើបអង្កេតបានច្រានចោលនូវសច្ចភាពមួយនេះ ដោយស្ងៀមស្ងាត់បំផុត។

៣. ការស៊ើបសួរលើថ្នាក់ដឹកនាំជាន់ខ្ពស់ និងអ្នកទទួលខុសត្រូវសំខាន់ៗលើឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តក្នុងអំឡុងពីថ្ងៃទី ១៧ មេសា ១៩៧៥ រហូតដល់ថ្ងៃទី ៦ មករា ១៩៧៩ គឺជាភារកិច្ចតែមួយ គត់ដែលប្រគល់ជូនសហចៅក្រមស៊ើបអង្កេតដោយច្បាប់ ដូច្នេះសហចៅក្រមស៊ើបអង្កេតត្រូវបំពេញភារកិច្ចខ្លួនក្នុងរង្វង់ក្របខណ្ឌនេះ។ វាជាការពិតហើយដែល សហចៅក្រមស៊ើបអង្កេតអាចធ្វើការស៊ើបអង្កេតផ្នែករដ្ឋបាលពាក់ព័ន្ធនឹងបញ្ហាពុករលួយ ប៉ុន្តែដោយហេតុថា រាជរដ្ឋាភិបាលកម្ពុជា និងភាគីអង្គការសហប្រជាជាតិជាអ្នកមានសមត្ថកិច្ចលើបញ្ហានេះ ដូច្នេះ តើមានប្រយោជន៍អ្វីទៅដែលធ្វើការស៊ើបអង្កេតនោះ?

៤. ទោះបីជាភាគីរាជរដ្ឋាភិបាលកម្ពុជា និងភាគីអង្គការសហប្រជាជាតិមិនដែលបានឯកភាពគ្នាចំពោះការដោះស្រាយបញ្ហានេះក៏ដោយ ហើយទោះបីជាលទ្ធផលនៃកិច្ចស៊ើបអង្កេតលើករណីនេះស្ថិតក្នុងភាពសម្ងាត់ ឬក៏ភាគីប្រទេសផ្តល់ជំនួយបានបញ្ឈប់ការផ្តល់ជំនួយដល់សាលាជម្រះក្តីមួយ នេះអស់រយៈពេលប៉ុន្មានខែមកហើយក្តី ក៏សហចៅក្រមស៊ើបអង្កេតបានប្រកាសថា បញ្ហាពុករលួយទោះបីវាពិតជាបានកើតឡើងមែន ឬមិនមែនក្តី មិនមែនជាបញ្ហាដែលត្រូវយកមកជំនុំជម្រះដោយតុលាការនោះ គឺសហចៅក្រមស៊ើបអង្កេតបានសម្អាងលើមូលហេតុសមស្របផ្អែកលើច្បាប់ និងភាពសមហេតុសមផល។

[1] ដីកាសម្រេចលើសំណើរសុំបំពេញកិច្ចស៊ើបសួររបស់សហចៅក្រមស៊ើបអង្កេត ចុះថ្ងៃទី ០៣ មេសា ឆ្នាំ ២០០៩, ឯកសារតុលាការលេខ D158/5 កថាខណ្ឌទី ១២ (ដែលពីនេះទៅហៅថា “ដីកាសម្រេច”)

៥. សេចក្ដីប្រកាសពុំទទួលស្គាល់សមត្ថកិច្ចរបស់ខ្លួននេះ ជាក់ស្ដែងគឺជាការបដិសេធមិនព្រមកាត់ក្ដីលើបញ្ហាអំពើពុករលួយនេះ។ អ្វីដែលធ្ងន់ធ្ងរនោះ គឺសេចក្ដីប្រកាសនេះហាក់ដូចជាមានគោលដៅធ្វើឱ្យការបដិសេធមិនព្រមកាត់សេចក្ដីនោះមានភាពស្របច្បាប់។ បច្ចុប្បន្ន ដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេតមួយនេះ ត្រូវបានធ្វើជាកម្មវត្ថុនៃការប្ដឹងឧទ្ធរណ៍ទៅអង្គបុរេជំនុំជម្រះ។ អង្គបុរេជំនុំជម្រះមិនត្រឹមតែទាត់ចោលសេចក្ដីប្រកាសអសមត្ថកិច្ចនោះប៉ុណ្ណោះទេ ប៉ុន្តែក៏គួរចាត់វិធានការដើម្បីបញ្ចប់ស្ថានភាពនៃអង្គហេតុដែលពាក់ព័ន្ធដល់ជនត្រូវចោទ ហើយជាពិសេសដើម្បីធានានូវ "សិទ្ធិទទួលបាននូវសិទ្ធិ" របស់លោក ខៀវ សំផន។

៦. ពិតមែនតែអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាមានលក្ខណៈ "វិសាមញ្ញ" តែយើងក៏មិនត្រូវធ្វើឱ្យអង្គជំនុំជម្រះនេះក្លាយទៅជាសាលាជម្រះក្ដីដែលមានលក្ខណៈ "ពិសេស" នោះដែរ!។

## II. <u>**វិធានច្បាប់ និងគោលការណ៍ដែលបានលើកឡើង**</u>

- បានឃើញច្បាប់របស់កម្ពុជាដែលកំពុងនៅជាធរមាន ដូចជារដ្ឋធម្មនុញ្ញ ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា និងសេចក្ដីសម្រេចរបស់ឧត្ដមក្រុមប្រឹក្សាជាន់ខ្ពស់ចុះថ្ងៃទី ១០ កញ្ញា ឆ្នាំ ១៩៩២ ស្ដីពីការរៀបចំស្ថាប័នតុលាការ នីតិព្រហ្មទណ្ឌ និងនីតិវិធីព្រហ្មទណ្ឌដែលសម្រាប់អនុវត្តក្នុងប្រទេសកម្ពុជានាសម័យអន្តរកាល (ដែលហៅថា "ច្បាប់អន្តរកាល")
- បានឃើញកិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ស្ដីពីបណ្ដឹងចំពោះជនដែលប្រព្រឹត្តឧក្រិដ្ឋកម្មក្នុងអំឡុងសម័យកាលនៃកម្ពុជាប្រជាធិបតេយ្យ (ដែលហៅថា"កិច្ចព្រមព្រៀង") ហើយនិងច្បាប់ស្ដីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាដើម្បីកាត់សេចក្ដីឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ (ដែលហៅថា " ច្បាប់ អវតក"។
- បានឃើញក្រមសីលធម៌តុលាការ
- បានឃើញមាត្រា ២ និង ១៤ នៃកតិកាសញ្ញាស្ដីពីសិទ្ធិពលរដ្ឋនិងសិទ្ធិនយោបាយ និងមាត្រា ៣៨ នៃសន្ធិសញ្ញាទីក្រុងវីយែន និងមាត្រា ៨ និង១០ នៃសេចក្ដីប្រកាសជាសាកលស្ដីពីសិទ្ធិមនុស្ស
- បានឃើញគោលការណ៍នៃនីតិអន្តរជាតិដែលហាមឃាត់ការបដិសេធមិនព្រមកាត់សេចក្ដី និងទ្រឹស្ដីនៃអំណាចដោយវាទរហិតដែលទ្រឹស្ដីបទនេះត្រូវបានទទួលស្គាល់យ៉ាងទូលំទូលាយក្នុងនីតិអន្តរជាតិ

៥. សេចក្តីប្រកាសពុំទទួលស្គាល់សមត្ថកិច្ចរបស់ខ្លួននេះ ជាក់ស្តែងគឺជាការបដិសេធមិនព្រមកាត់ក្តីលើបញ្ហាអំពើពុករលួយនេះ។ អ្វីដែលធ្ងន់ធ្ងរនោះ គឺសេចក្តីប្រកាសនេះហាក់ដូចជាមានគោលដៅធ្វើឲ្យការបដិសេធមិនព្រមកាត់សេចក្តីនោះមានភាពស្របច្បាប់។ បច្ចុប្បន្ន ដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេតមួយនេះ ត្រូវបានធ្វើជាកម្មវត្ថុនៃការប្តឹងឧទ្ធរណ៍ទៅអង្គបុរេជំនុំជម្រះ។ អង្គបុរេជំនុំជម្រះមិនត្រឹមតែទាត់ចោលសេចក្តីប្រកាសអសមត្ថកិច្ចនោះប៉ុណ្ណោះទេ ប៉ុន្តែក៏គួរចាត់វិធានការដើម្បីបញ្ចប់ស្ថានភាពនៃអង្គហេតុដែលពាក់ព័ន្ធដល់ជនត្រូវចោទ ហើយជាពិសេសដើម្បីធានានូវ "សិទ្ធិទទួលបាននូវសិទ្ធិ" របស់លោក ខៀវ សំផន។

៦. ពិតមែនតែអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាមានលក្ខណៈ "វិសាមញ្ញ" តែយើងក៏មិនត្រូវធ្វើឲ្យអង្គជំនុំជម្រះនេះក្លាយទៅជាសាលាជម្រះក្តីដែលមានលក្ខណៈ "ពិសេស" នោះដែរ!។

## II. វិធានច្បាប់ និងគោលការណ៍ដែលបានលើកឡើង

- បានឃើញច្បាប់របស់កម្ពុជាដែលកំពុងនៅជាធរមាន ដូចជារដ្ឋធម្មនុញ្ញ ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា និងសេចក្តីសម្រេចរបស់ឧត្តមក្រុមប្រឹក្សាជាន់ខ្ពស់ចុះថ្ងៃទី ១០ កញ្ញា ឆ្នាំ ១៩៩២ ស្តីពីការរៀបចំស្ថាប័នតុលាការ នីតិព្រហ្មទណ្ឌ និងនីតិវិធីព្រហ្មទណ្ឌដែលសម្រាប់អនុវត្តក្នុងប្រទេសកម្ពុជានាសម័យអន្តរកាល (ដែលហៅថា "ច្បាប់អន្តរកាល")
- បានឃើញកិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ស្តីពីបណ្តឹងចំពោះជនដែលប្រព្រឹត្តឧក្រិដ្ឋកម្មក្នុងអំឡុងសម័យកាលនៃកម្ពុជាប្រជាធិបតេយ្យ (ដែលហៅថា"កិច្ចព្រមព្រៀង") ហើយនិងច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ (ដែលហៅថា " ច្បាប់ អវតក"។
- បានឃើញក្រមសីលធម៌តុលាការ
- បានឃើញមាត្រា ២ និង ១៤ នៃកតិកាសញ្ញាស្តីពីសិទ្ធិពលរដ្ឋនិងសិទ្ធិនយោបាយ និងមាត្រា ៣៨ នៃសន្ធិសញ្ញាទីក្រុងវីយ៉ែន និងមាត្រា ៨ និង១០ នៃសេចក្តីប្រកាសជាសាកលស្តីពីសិទ្ធិមនុស្ស
- បានឃើញគោលការណ៍នៃនីតិអន្តរជាតិដែលហាមឃាត់ការបដិសេធមិនព្រមកាត់សេចក្តី និងទ្រឹស្តីនៃអំណាចដោយវាទរហិតដែលទ្រឹស្តីបទនេះត្រូវបានទទួលស្គាល់យ៉ាងទូលំទូលាយក្នុងនីតិអន្តរជាតិ

## III. កំណត់សម្គាល់បឋម

៧. អង្គបុរេជំនុំជម្រះបានទទួលបណ្ដឹងឧទ្ធរណ៍នេះស្របតាមវិធាន ៧៤.៣.ខ ៥៥.១០ និង ៣៥.៦នៃវិធានផ្ទៃក្នុង។ ក្នុងក្របខណ្ឌនេះ ក្រុមមេធាវីការពារសូមរំលឹកផងដែរថា អង្គបុរេជំនុំជម្រះ "អាចទុកជាមោឃៈដោយឯកឯង នូវនីតិវិធីទាំងមូល ឬផ្នែកណាមួយ"[2] និងអាច "បង្គាប់ឱ្យមានកិច្ចស៊ើបសួរបំពេញបន្ថែម តាមដែលខ្លួនយល់ឃើញថាមានប្រយោជន៍"[3] ហើយនិងអាចទទួលស្គាល់កាតព្វកិច្ច និង សមត្ថកិច្ចនេះ នៅក្នុងសេចក្ដីសម្រេចរបស់ខ្លួនចុះថ្ងៃទី ៣ ខែធ្នូ ឆ្នាំ ២០០៧ [4]។ ក្រុមមេធាវីការពារក៏បានលើកឡើងផងដែរ ពីភាពចំបាច់ដែលអង្គបុរេជំនុំជម្រះត្រូវ "ធានាថា នីតិវិធីដែលបានអនុវត្តក្នុងកិច្ចស៊ើបសួរត្រូវប្រព្រឹត្តទៅដោយសមធម៌" [5] ។

## IV. អំណះអំណាង

- **អំពើពុករលួយ និងយុត្តិធម៌**

៨. ពាក្យទាំងពីរម៉ាត់នេះ បើយើងដាក់វាទន្ទឹមគ្នាមើលទៅ វាមានលក្ខណៈប្រឆាំងគ្នាទៅវិញទៅមកបើផ្អែកតាមអត្ថន័យបែបអក្សរសាស្ត្រ។ ពាក្យទីមួយមានលក្ខណៈបដិមតិទៅនឹងពាក្យទីពីរ ពោលគឺបើមានពាក្យទីមួយ គឺគ្មានពាក្យទីពីរ។ ជាមួយគ្នានេះដែរ ប្រសិនបើយើងនិយាយអំពីពាក្យថា "អំពើពុករលួយ" និង "យុត្តិធម៌" គឺយើងមិនអាចនិយាយអំពី "យុត្តិធម៌ដែលជិតដាមដោយអំពើពុករលួយ" ថាជាយុត្តិធម៌ដែលពិតប្រាកដនោះឡើយ។

៩. ក្នុងភាសាខ្មែរ ពាក្យថា " អំពើពុករលួយ" កើតចេញពីការបូកផ្សំនៃពាក្យបីផ្សេងគ្នាៈ ទីមួយពាក្យ "អំពើ" បូកនិង " ពុក" បូកនិង "រលួយ"។ ក្នុងភាសាបារាំង និងអង់គ្លេស ពាក្យ "អំពើពុករលួយ" មានប្រភពមកពីភាសាឡាតាំង ដែលហៅថា "*Cum*" ដែលមានន័យថា "ទាំងមូល" និងពាក្យ "*Rupere*" ដែលមានន័យថា "ការផ្ដាច់ ការធ្វើឱ្យបាក់បែក"។ ដូច្នេះ "ពុករលួយ" មានន័យថា

---

[2] មាត្រា ២៦១ នៃក្រមនីតិវិធីព្រហ្មទណ្ឌនៃ ព្រះរាជាណាចក្រកម្ពុជា

[3] មាត្រា ២៦២ នៃក្រមនីតិវិធីព្រហ្មទណ្ឌនៃ ព្រះរាជាណាចក្រកម្ពុជា

[4] សេចក្ដីសម្រេចលើបណ្ដឹងឧទ្ធរណ៍ជំទាស់ទៅនឹងដីកាឃុំខ្លួនបណ្ដោះអាសន្នលោក កាំង ហ្គេចអ៊ាវ ហៅ ឌុច ឯកសារតុលាការលេខ C5/45 កថាខណ្ឌទី ៧

[5] ដីកាសម្រេចលើបណ្ដឹងឧទ្ធរណ៍របស់លោក ខៀវ សំផន ប្រឆាំងនឹងដីកាសម្រេចកំណត់សិទ្ធិ និងកាតព្វកិច្ចរបស់ភាគីទាក់ទងនឹងការបកប្រែ។ ថ្ងៃទី ២០ កុម្ភៈ ឆ្នាំ ២០០៨ ឯកសារតុលាការលេខ A 190/I/20 កថាខណ្ឌទី ៣៦

" បំបែកបំបាក់ទាំងស្រុង"។ ដូច្នេះពាក្យនេះមានអត្ថន័យទូទៅចង់សម្តៅទៅដល់ " ដំណើរការខូច ការធ្វើឱ្យព្រលឹងប្រែជារលេះរលួយ" [6]។

១០. ពាក្យថា អំពើពុករលួយត្រូវបានឱ្យនិយមន័យជាទូទៅថា ជា "ការរំលោភនូវតួនាទីក្នុងរាជការសាធារណៈ ដើម្បីបម្រើឱ្យផលឯកជន" [7]។ អំពើពុករលួយក្នុងស្ថាប័នតុលាការត្រូវបានចាត់ទុកជាបទឧក្រិដ្ឋ បើផ្អែកតាមច្បាប់របស់កម្ពុជា[8]។ អំពើនេះត្រូវបានបណ្តារដ្ឋនានាក្នុងសហគមន៍អន្តរជាតិកំពុងធ្វើការប្រយុទ្ធប្រឆាំងក្រោមការគាំពាររបស់អង្គការសហប្រជាជាតិ[9] ហើយក៏ត្រូវបានហាមឃាត់ផងដែរដោយក្រមសីលធម៌តុលាការ[10] មិនតែប៉ុណ្ណោះវាជាទង្វើដែលប្រាសចាកសីលធម៌ផងដែរ។ លើសពីអ្វីដែលបានកំណត់ដោយនិយមន័យ អំពើពុករលួយគឺជាសភាវៈដែល ប្រឆាំងទៅនឹងសញ្ញាណនៃយុត្តិធម៌ ឬប្រឆាំងទៅនឹងដំណើរការកសាងនីតិរដ្ឋ។

១១. ពីព្រោះថា អំពើពុករលួយវាជាការរំលាយចោលនូវកិច្ចសន្យាសង្គម (Pacte social) ដែលកិច្ចសន្យានេះស្តែងឡើងជាកិច្ចព្រមព្រៀង ដែលបានផ្តល់នូវបុព្វសិទ្ធិនៃអំណាចសាធារណៈដែលបុគ្គលណាមួយ ព្រមទាំងអនុញ្ញាតឱ្យបុគ្គលនោះមានសិទ្ធិអំណាចក្នុងការអនុវត្តបុព្វសិទ្ធិនោះផងដែរ។ អំពើពុករលួយវាក៏ជាឧបសគ្គធ្វើឱ្យរាំងស្ទះដល់ការសម្រេចគោលដៅនៅស្ថាប័ន ដែលអំពើនោះបានកើត

---

[6] Eric Alt & Irène Luc, *ការប្រឆាំងនឹងអំពើពុករលួយ*, Presses Universitaire de France, ទំព័រទី៣

[7] និយមន័យនៃអង្គការក្រៅរដ្ឋាភិបាល "Transparency International" សង្ខេបរបាយការណ៍ពិភពលោកស្តីពីអំពើពុករលួយឆ្នាំ ២០០៧ ទំព័រទី១

[8] មាត្រា ៣៨ ស្តីពីអំពើពុករលួយ នៃសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាជាតិជាន់ខ្ពស់ចុះថ្ងៃទី ១០ កញ្ញា ឆ្នាំ ១៩៩២ ស្តីពីប្រព័ន្ធតុលាការ នីតិព្រហ្មទណ្ឌ និងនីតិវិធីព្រហ្មទណ្ឌសម្រាប់អនុវត្តក្នុងប្រទេសកម្ពុជាក្នុងសម័យអន្តរកាល៖ ដោយមិនគិតដល់ទណ្ឌកម្មខាងវិស័យជាយថាហេតុ គ្រប់អ្នករដ្ឋបាលស៊ីវិល ឬយោធាគ្រប់ភ្នាក់ងារផ្លូវការរបស់ភាគីណាមួយ ក្នុងចំណោមភាគីទាំងបួននៃកិច្ចព្រមព្រៀងក្រុងប៉ារីស គ្រប់អ្នកទទួលខុសត្រូវនយោបាយដែលស្នើសុំ ឬប៉ុនប៉ងនឹងស្នើសុំ ឬទទួល ឬប៉ុនប៉ងនឹងទទួល ក្នុងក្របខណ្ឌនៃមុខងារខ្លួន ឬក្នុងឱកាសបំពេញការងារនូវទ្រព្យសម្បត្តិ សេវាកម្ម ប្រាក់កាស បុគ្គលមុខងារ ឯកសារ សេចក្តីអនុញ្ញាត ឬប្រយោជន៍អ្វីមួយ ជាថ្នូរនៃរបស់ណាមួយក្នុងចំណោមរបស់ទាំងនេះ គឺបានប្រព្រឹត្តបទឧក្រិដ្ឋស៊ីសំណូកអកម្ម ហើយត្រូវផ្តន្ទាទោសដាក់គុកជាបទឧក្រិដ្ឋពី៣ឆ្នាំ ទៅ៧ឆ្នាំ។"

[9] កិច្ចព្រមព្រៀងរបស់អង្គការសហប្រជាជាតិប្រឆាំងនឹងអំពើពុករលួយ ដែលត្រូវបានចុះហត្ថលេខាដោយប្រទេសកម្ពុជាកាលពីថ្ងៃទី ៥ ខែកញ្ញា ឆ្នាំ ២០០៧

[10] មាត្រា ៣.១ នៃក្រមសីលធម៌តុលាការដែលត្រូវបានអនុម័តដោយកិច្ចប្រជុំពេញអង្គនៃ អវតក "ទោះបីដោយផ្ទាល់ក្តី ដោយប្រយោលក្តី ចៅក្រមមិនត្រូវទទួលសំណូក អត្ថប្រយោជន៍ ឬការតបស្នងណាមួយ ដែលត្រូវបានមើលឃើញថា មានគោលដៅក្នុងការប្រើឥទ្ធិពលលើការបំពេញមុខងាររបស់ខ្លួន"។

ឡើង។ ដោយគ្មានភាពថ្លៃថ្នូរបន្តិចណាសោះ ដែលយកអំណាចដែលគេប្រគល់ឲ្យទៅប្រព្រឹត្តអំពើដូច្នោះ អំពើពុករលួយដែលជាគោលការណ៍អាចបម្រើផលប្រយោជន៍ជនគ្រប់រូប វាពឹងផ្អែកទាំងស្រុងទៅលើឆន្ទៈរបស់ជនណាមួយ ហើយដែលឆន្ទៈនោះមានលក្ខណៈផ្ទុយទៅនឹងច្បាប់។

១២. យើងអាចយល់បានយ៉ាងច្បាស់ថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិនៃ អវតក លោកចៅក្រម Marcel LEMONDE បានលើកឡើងដោយចំៗតែម្តង អំពីបញ្ហានៃអំពើពុករលួយនេះនៅចំពោះមុខ អវតក៖

"ចៅក្រមអន្តរជាតិនានាបានប្រកាសថា ពួកគាត់មិនអាចចូលរួមក្នុងដំណើរការកាត់សេចក្តីដែលមិនមានសមធម៌នៅចំពោះមុខតុលាការដែលឯករាជ្យ និងអនាគតិ (...)។ លក្ខខណ្ឌអស់ទាំងនេះមិនអាចសម្រុះសម្រួលបានឡើយ តែផ្ទុយទៅវិញ បើសិនលក្ខខណ្ឌអស់ទាំងនោះមិនត្រូវបានបំពេញទេ ចៅក្រមបរទេសទាំងឡាយនឹងគ្មានជម្រើសអ្វីក្រៅស្នើសុំឲ្យអង្គការសហប្រជាជាតិដកចេញនោះឡើយ (...) ការដកចេញនេះពុំមែនជាការគម្រាមកំហែង ដែលមានគោលដៅដាក់គូភាគីឲ្យទាល់ច្រកនោះឡើយ វាជាអង្គហេតុមួយ។" [11]

១៣. ផ្ទុយទៅវិញ វាគ្មានការពិតទាល់តែសោះ ដែលគិតថាអំពើពុករលួយនៅពេលដែលគេរកឃើញថាបានកើតមានឡើង គ្មានគោលដៅធ្វើឲ្យស្ថាប័នតុលាការបាត់បង់កិត្យានុភាពនោះឡើយ។ ត្រូវមានការស្វែងរកយុត្តិធម៌ ប៉ុន្តែយុត្តិធម៌នេះត្រូវផ្តល់ឲ្យជនគ្រប់រូប នេះគឺជាពាក្យស្លោក។ វាជាការគ្រប់គ្រាន់ដែលភាពស្រពិចស្រពិលនេះដក់ក្នុងសតិអារម្មណ៍របស់សាធារណជន ហើយជាពិសេសក្នុងសតិអារម្មណ៍របស់ជនត្រូវចោទ ដើម្បីឲ្យសមធម៌ទាំងឡាយត្រូវបានបាត់បង់ ហើយដោយសារសមធម៌នេះ គេមានសង្ឃឹមថានឹងអាចធ្វើការកាត់សេចក្តីប្រកបដោយសមធម៌បាន។

១៤. ជាក់ស្តែង ប្រភពភស្តុតាងនានាដែលអាចបញ្ជាក់ពីអំពើពុករលួយ ចម្លើយបង្វែងដានរបស់អាជ្ញាធរ ហើយនិងការបដិសេធប្រឆាំងទៅនឹងកិច្ចខិតខំប្រឹងប្រែងរបស់ក្រុមមេធាវីការពារក្តីលោក នួន ជា[12] គឺបានសរបញ្ជាក់ច្បាស់នូវការកើតឡើងនៃអំពើពុករលួយ នេះបើសិនជាអំពើនោះត្រូវបានលើកភស្តុតាងមកបង្ហាញក្នុងរង្វង់ អវតក។

---

[11] Cat Barton, *"Kickback Claims stain the KRT"* កាសែត *The Phnom Penh Post* ថ្ងៃទី ២៣ ខែ កុម្ភៈ ឆ្នាំ ២០០៧

[12] សូមយោងទៅដល់ការសរសេររៀបរាប់នៅក្នុងសំណើសុំបើកកិច្ចស៊ើបសួរលើកទី១១ ដែលបានដាក់ដោយក្រុមមេធាវីការពារក្តី នួន ជា និងដែលមានការចូលរួមផងដែរដោយក្រុមមេធាវីការពារក្តី ខៀវ សំផន តាមរយៈសំណើសុំបើកកិច្ចស៊ើបសួរលើកទី ១១ ចុះថ្ងៃទី ២៧ ខែ មីនា ឆ្នាំ ២០០៩ *ឯកសារតុលាការ D158*

- **អំពីសមត្ថកិច្ចរបស់ចៅក្រមស៊ើបអង្កេត ឬអំពីការដាក់ឱ្យស្ថិតនៅក្រោមច្បាប់**

១៥. នៅចំពោះមុខស្ថានភាពនេះ សហចៅក្រមស៊ើបអង្កេតបានសន្និដ្ឋានថា ការបន្តកិច្ចស៊ើបសួរ និងកាតព្វកិច្ចរបស់ពួកគាត់ក្នុង*ការស្វែងរកយុត្តិធម៌* មិនមែនស្តែងឡើងជាពិសេសលើការចាត់ឱ្យមានការផ្តោះប្តូរផ្នែកឯកសារ ដែលជាជំហានឈានទៅរកការបំភ្លឺលើករណីចោទប្រកាន់អំពីអំពើពុករលួយលើបុគ្គលិកនៅ អវតក នោះឡើយ។

១៦. ដោយធ្វើយ៉ាងដូច្នេះ សហចៅក្រមស៊ើបអង្កេតបានលើកឡើងអំពីការដាក់ខ្លួនឯងឱ្យស្ថិតនៅក្រោមច្បាប់ ដើម្បីធ្វើជាមូលដ្ឋានបញ្ជាក់អំពីអសមត្ថកិច្ចរបស់ខ្លួន និងគោលការណ៍គ្រឹះនៃនីតិរដ្ឋ។ តើគោលការណ៍មួយអាចបង្កើតជាការអនុវត្តន៍ជាច្រើន ដែលការអនុវត្តន៍ទាំងនោះអាចគំរាមកំហែងដល់អត្ថិភាពរបស់គោលការណ៍នោះដែរឬទេ? តាមពិត ការប្រកាសពីអសមត្ថកិច្ចរបស់ខ្លួនដោយយកមូលដ្ឋានច្បាប់ជាសម្អាង សហចៅក្រមស៊ើបអង្កេតមិនបានគោរព ឋានានុក្រមនៃបទដ្ឋានគតិយុត្តិឡើយ។ ដោយមិនបានគោរពតាមគោលការណ៍នៃនីតិរដ្ឋ សហចៅក្រមស៊ើបអង្កេតបានច្រានចោលនូវភាពសមហេតុសមផលផ្នែកខាងក្រោយមួយ។

១៧. ជាមួយគ្នានេះដែរ មិនមែនដោយសារអំណាចតុលាការឯករាជ្យ និងអនាគតិ[13]ទៀតទេ ដែល អវតក មានសមត្ថកិច្ចក្នុង*ការស្វែងរកយុត្តិធម៌* ប៉ុន្តែគឺដោយសារច្បាប់ដែលកើតចេញពីឆន្ទៈរបស់គូភាគីជាអ្នកកំណត់ពីសមត្ថកិច្ចនេះ។ ជាមួយគ្នានេះដែរ ការដែលសហចៅក្រមស៊ើបអង្កេតមានសមត្ថកិច្ចក្នុងការស៊ើបសួរ គឺមិនមែនដោយសារតែចៅក្រមស៊ើបអង្កេតជាអ្នកថែរក្សានូវសេរីភាពបុគ្គល និងសមធម៌នោះទេ ក៏ប៉ុន្តែដោយសារច្បាប់ជាអ្នកប្រគល់តួនាទីនេះដល់ពួកគាត់។ គ្មានអ្វីដែលគួរឱ្យងឿងឆ្ងល់នោះទេ ដែលថា ការលាតត្រដាងការពិតពីក្នុងសម័យឆ្នាំ ១៩៧៥ ដល់ឆ្នាំ ១៩៧៩ ត្រូវបានធ្វើហួសពីទម្រង់នៃការពិនិត្យដ៏ល្អិតល្អន់ និងវៀចាកនូវភាពសមហេតុសមផល ទោះជាភាពសមហេតុសមផលនោះមានលក្ខណៈជាគតិយុត្តិក្តី ឬមានលក្ខណៈជាក្រមសីលធម៌ក្តី !

---

[13] ផ្ទុយទៅវិញមាត្រា ១០៩ នៃរដ្ឋធម្មនុញ្ញចែងថា៖ "អំណាចតុលាការជាអំណាចឯករាជ្យ។ អំណាចតុលាការធានារក្សាអនាគតិ និងការពារសិទ្ធិសេរីភាពរបស់ប្រជាពលរដ្ឋ។ អំណាចនេះត្រូវប្រគល់ឱ្យតុលាការកំពូល និងសាលាជំរះក្តីគ្រប់ជាន់ថ្នាក់"។ (...) មានតែចៅក្រមទេដែលមានសិទ្ធិជម្រះក្តី។ ចៅក្រមត្រូវបំពេញភារកិច្ចនេះដោយគោរពច្បាប់យ៉ាងម៉ឺងម៉ាត់ និងឱ្យអស់ពីដួងចិត្ត និងសម្បជញ្ញៈរបស់ខ្លួន (មាត្រា ១១០)"។ (គូសបន្ទាត់ពីក្រោមដោយពួកយើងខ្ញុំ)

១៨. ដើម្បីរក្សាអត្តសញ្ញាណជាតុលាការ និងការពារតួនាទីជាសាលាជម្រះក្តី តុលាការអន្តរជាតិនានា ជាពិសេសតុលាការ *ad hoc* បានចាត់ទុកថាសមត្ថកិច្ចរបស់ខ្លួនត្រូវតែស្ថិតនៅខ្ពស់ជាងឆន្ទៈរបស់អ្នកដែលបង្កើតតុលាការនេះ[14]។ ចំពោះតុលាការយុត្តិធម៌អន្តរជាតិ (CJI) " គឺតុលាការនេះខ្លួនឯងតែម្តង (...) ដែលជាអ្នកធានានូវអធិបតេយ្យភាពនៃមុខងាររបស់តុលាការ ក្នុងតុលាការយុត្តិធម៌អន្តរជាតិ"[15]។ ក្នុងនាមជាសាលាជម្រះក្តី តុលាការនេះមានអំណាចសម្រេចរឿងទាំងនេះ[16]។

១៩. អវតក "មានលក្ខណៈខុសគ្នាពីសាលាជម្រះក្តីនានានៅកម្ពុជា ហើយ អវតក គឺជាស្ថាប័នមួយដែលឯករាជ្យក្នុងរង្វង់ស្ថាប័នជម្រះក្តីនៅកម្ពុជា" ហើយ អវតក មានលក្ខណៈជាតុលាការអន្តរជាតិ [17]។ ក្នុងនាមជាចៅក្រមនៃ អវតក និងដោយអនុវត្តទ្រឹស្តីនៃអំណាចដែលមិនមានចែងយ៉ាងជាក់លាក់ សហចៅក្រមស៊ើបអង្កេតមិនត្រឹមតែមាន "សមត្ថកិច្ចក្នុងការកំណត់អំពីសមត្ថកិច្ចរបស់ខ្លួន"[18]តែប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងមានអំណាចដែលមិនមានចែងយ៉ាងជាក់លាក់ ក្នុងការចាត់

---

[14] ដូចនេះនៅក្នុង *ដីកាសម្រេចអំពីបណ្តឹងឧទ្ធរណ៍របស់ក្រុមមេធាវីការពារក្តីទាក់ទងនឹងបញ្ហាអសមត្ថកិច្ចនៃអង្គតុលាការ* នៅក្នុងរឿងក្តី *រដ្ឋអាជ្ញា ទល់នឹង* Dusko Tadic ចុះថ្ងៃទី ០២ តុលា ឆ្នាំ ១៩៩៥ ចៅក្រមនៃសាលាឧទ្ធរណ៍បានលើកឡើងនៅក្នុងកថាខណ្ឌ ១៥ យ៉ាងដូច្នេះថា *"ឧទាហរណ៍ថា សមត្ថកិច្ចនៃតុលាការអន្តរជាតិត្រូវបានកំហិតយ៉ាងតឹងរឹងត្រឹម "ឆន្ទៈ" របស់ក្រុមប្រឹក្សាសន្តិសុខ* ដូច្នេះវាគ្រាន់តែជា "ស្ថាប័នចំណុះ" មួយរបស់ក្រុមប្រឹក្សាសន្តិសុខ តែប៉ុណ្ណោះ (...) "ការបង្កើតស្ថាប័នមួយ" ដែលឋិតនៅក្នុងការគិតគូរដ៏សែនល្អិតល្អន់របស់"អ្នកបង្កើត"វា ហើយឋិតនៅក្រោមអំណាច និងការអនុគ្រោះរបស់អ្នកបង្កើតនេះទាំងស្រុង។ ប៉ុន្តែក្រុមប្រឹក្សាសន្តិសុខមិនបានសម្រេចចិត្តត្រឹមតែបង្កើតស្ថាប័នចំណុះប៉ុណ្ណោះទេ (...) ក្រុមប្រឹក្សានេះក៏មានឆន្ទៈច្បាស់លាស់ផងដែរក្នុងការបង្កើតឲ្យមានស្ថាប័នចំណុះមួយប្រភេទពិសេសគឺ៖ តុលាការ" និង លេខ ១៨

[15] រឿងក្តី Cameroun Septentrional (ប្រទេសកាមេរូន ទល់នឹង ប្រទេសអង់គ្លេស) បញ្ហាមុនអង្គសេចក្តី ដីកាសម្រេច កម្រងឯកសារ C.I.J ឆ្នាំ ១៩៦៣ ទំព័រ ១៥ ទំព័រ ២៩។

[16] ទាក់ទងនឹងអំណាចនេះ អង្គការអន្តរជាតិ និងតុលាការអន្តរជាតិ កំណត់ថាជា "អំណាចដោយឯកឯង"។ ទ្រឹស្តីនៃ អំណាចនេះជាទ្រឹស្តីនៅក្នុងនីតិអន្តរជាតិ ព្រោះត្រូវបានកំណត់ទទួលស្គាល់ដោយច្បាស់លាស់ដោយតុលាការយុត្តិធម៌អន្តរជាតិ ក្នុងសេចក្តីសន្និដ្ឋានមួយ ឆ្នាំ (Avis) ១៩៤៩ (Nguyen Quoc Dinh នីតិអន្តរជាតិសាធារណៈ ១៩៩៩ ទំព័រ ៥៩៧)

[17] សេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្ន កាំង ហ្កេកអ៊ាវ ហៅ ឌុច *ឯកសារ តុលាការ C5/45* កថាខណ្ឌ ២០៖ បញ្ហាដែលលើកឡើងនោះរួមមាន "ដោយសារតុលាការត្រូវបានបង្កើតឡើងដោយសន្ធិសញ្ញាមួយ។ ការបង្កើតតុលាការនេះ គឺជាការសម្តែងឆន្ទៈរបស់សហគមន៍អន្តរជាតិដែលជាផ្នែកមួយនៃយន្តការស្វែងរកយុត្តិធម៌អន្តរជាតិ ហើយមានយុត្តាធិការក្នុងការកាត់សេចក្តីឧក្រិដ្ឋកម្មអន្តរជាតិធ្ងន់ធ្ងរ"។

[18] អង្គជំនុំជម្រះសាលាឧទ្ធរណ៍នៃតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតយូហ្គោស្លាវី, ព្រះរាជអាជ្ញា ប្តឹងទល់នឹង *Dusko Tadic alias Dule* សាលដីកាសម្រេចលើបណ្តឹងឧទ្ធរណ៍របស់មេធាវីការពារ ទាក់ទងដល់ករណីអញ្ញត្រកម្មលើអសមត្ថកិច្ច ចុះថ្ងៃទី ២ ខែ តុលា ឆ្នាំ ១៩៩៥ កថាខណ្ឌទី ១៨។

វិធានការណ៏ចាំបាច់ ដើម្បីធានានូវការអនុវត្តន៍សមត្ថកិច្ចចម្បងរបស់ខ្លួនឲ្យមានប្រសិទ្ធិភាព[19]។ ក្នុងវង្វង់ការអនុវត្តអំណាចដោយឯកឯងដ៏ទៃទៀត ចៅក្រមក៏មានលទ្ធភាពធ្វើនិយតកម្មទៅលើនីតិវិធី ដើម្បីធានាបាននូវប្រសិទ្ធិភាពនៃការអនុវត្តន៏តួនាទីរបស់ខ្លួនក្នុងនាមជាសាលាជម្រះក្តី[20] ឬមួយក៏ចាត់វិធានការណ៍បណ្តោះអាសន្ននានាតាមដែលអាចធ្វើទៅបាន [21]។

២០. ដោយមិនបានលើកឡើងយ៉ាងជាក់ច្បាស់ពីទ្រឹស្តីនៃអំណាចដែលមិនមានចែង សហចៅក្រមស៊ើបអង្កេតបានអនុវត្តទ្រឹស្តីនៃអំណាចដោយមិនអាចបង្ហាញនេះរួចបាត់ទៅហើយ នៅពេលដែលខ្លួនបានសម្រេចទាក់ទងដល់សិទ្ធិ និងកាតព្វកិច្ចរបស់គូរភាគីពាក់ព័ន្ធនឹងការបកប្រែ ដោយហេតុថា "បញ្ហា (...) នេះគឺជាបញ្ហាដែលពាក់ព័ន្ធនឹងប្រយោជន៏ទូទៅ " [22]។

---

19 "អំណាចក្នុងការកំណត់ជាផ្លូវការគឺជាអំណាចដែលមិនអាចកាត់ផ្តាច់បាន៖ តុលាការអន្តរជាតិត្រូវប្រកាន់នូវអំណាចក្នុងការធ្វើនូវរបាយការណ៍ជាផ្លូវការដែលចាំបាច់ក្នុងការបំពេញមុខងាររបស់ខ្លួន។ អំណាចដែលមិនអាចកាត់ផ្តាច់បាននេះ ត្រូវបានអនុវត្តជាអត្ថប្រយោជន៏ដល់តុលាការអន្តរជាតិ ដើម្បីអនុញ្ញាតឲ្យតុលាការនេះអាចបំពេញតួនាទីរបស់ខ្លួនជាសាលាជម្រះក្តីពេញលក្ខណ: ហើយដែលតួនាទីនេះក៏គួរទទួលបានការគាំពារផងដែរ។" សាលាឧទ្ធរណ៍នៃ ICTY ព្រះរាជអាជ្ញាប្តឹងទល់នឹង Tihomir Blaskic, បណ្តឹងឧទ្ធរណ៍ទាក់ទងនឹងបណ្តឹងរបស់សាធារណៈរដ្ឋក្រូអាតស៊ី ក្នុងគោលដៅធ្វើការពិនិត្យសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង II ចុះថ្ងៃទី ១៨ កក្កដា ឆ្នាំ ១៩៩៧ និង ២៩ តុលា ឆ្នាំ ១៩៩៧។ កថាខណ្ឌទី ៣៣។ សូមពិនិត្យមើលសំណុំរឿង ការសាកល្បងអាវុធនុយក្លេអ៊ែរ (ប្រទេសនូវែលហ្សេឡង់ ប្តឹងប្រទេសបារាំង), សាលដីការបស់តុលាការព្រហ្មទណ្ឌអន្តរចាតិចុះថ្ងៃទី ២០ ធ្នូ ឆ្នាំ ១៩៧៤ កថាខណ្ឌទី ២៣ " (...) សូមរំលឹកផងដែរថាអង្គជំនុំជម្រះមានអំណាចដែលមិនអាចកាត់ផ្តាច់បានដែលអនុញ្ញាតិអោយអង្គជំនុំជម្រះអាចចាត់វិធានការណ៏តាមត្រូវការ។ ម្យ៉ាង ដើម្បីធានាថាការអនុវត្តសមត្ថកិច្ចត្រូវធ្វើឡើងដោយពិតប្រាកដ ប្រសិនណាបើសមត្ថកិច្ចលើអង្គសេចក្តីត្រូវបានលើកឡើង។ ម្យ៉ាងទៀតដើម្បីធានាការកាត់សេចក្តីដោយទៀងទាត់នូវគ្រប់ចំណុចនៃរឿងក្តី និងការគោរពដល់ " ដែនកំណត់ដែលមិនអាចកាត់ផ្តាច់បាននៃការបំពេញមុខងារតុលាការ" របស់អង្គជំនុំជម្រះ និងដើម្បីថែររក្សាចារឹកលក្ខណ:ជាសាលាជំរះក្តី" (*Cameroun septentrional, សាលដីកា* C.I.J Recueil 1963, ទំព័រទី ២៩)។ អំណាចដែលមិនអាចកាត់ផ្តាច់បាននេះ ដែលឈរលើមូលដ្ឋាននេះ អង្គជំនុំ ជម្រះមាននីតិសម្បទាគ្រប់គ្រាន់ ក្នុងការអនុម័តសេចក្តីសន្និដ្ឋាននាពេលអនាគតដែលឆ្លើយតបចាំបាច់ទៅនឹងគោលដៅដែលទើប នឹងលើកឡើង ដែលកើតចេញពីការកកើតរដ្ឋ និងត្រូវបានប្រគល់ជូនដើម្បីឲ្យមុខងារចម្បងក្នុងនាមជាសាលាជម្រះក្តីត្រូវបានទទួលការគាំពារ។

20 *Joseph Kanyabashi v The Prosecutor,* ICTR-96-15-A, Appeals Chamber II: Dissenting Opinion of Judge Shahabudeen, 3 June 1999, « a judicial body, whether civil or criminal »possesses « the inherent competence… to regulate its own procedure, in the event of silence in the written rules, so as to assure the exercise of such jurisdiction, as it has, and to fulfill itself, properly and effectively, as a court of law" (p. 17)

21 សូមមើល Paola Gaeta, « Inherent Powers of International Courts and Tribunals » dans L.C. Vohrah et al (Eds.) *Man's Inhumanity to Man : Essays on International Law in Honour of Antonio Cassesse,* 2003, p. 357 (http://books.google.fr/books?id=AhYtpy2Rn3wC&printsec=frontcover&source=gbs_summary_r&cad=0#PPA353,M1)

22 ដីកាសម្រេចស្តីពីសិទ្ធិនិងកាតព្វកិច្ចរបស់ភាគីពាក់ព័ន្ធដល់ការបកប្រែ, ឯកសារតុលាការ A190 , សេចក្តីផ្តើម

២១. បន្ថែមពីលើបញ្ហានៃអត្ថប្រយោជន៍ទូទៅដែលចោទឡើង អំពើពុករលួយ ទោះបីជាបានកើតឡើង ឬមួយត្រូវបានសន្មត់ថាបានកើតមានឡើងក៏ដោយ ក៏វាបានបំផ្លាញយន្តការនៃការស្វែងរកយុត្តិធម៌ទាំងស្រុង។ វាបានធ្វើឲ្យប៉ះពាល់ដល់កេរ្តិ៍ឈ្មោះរបស់ស្ថាប័នទាំងមូល ដោយធ្វើឲ្យស្ថាប័ននេះបាត់បង់សមត្ថភាពក្នុងការស្វែងរកយុត្តិធម៌ប្រកបដោយសមធម៌ និងមិនត្រូវបានគេមើលឃើញថាជាស្ថាប័នស្វែងរកយុត្តិធម៌ទៀតទេ។ តើនេះជាសមត្ថកិច្ចចំបងរបស់ អវតក ទៅឬ?

២២. នៅក្នុងករណីនេះ អំពើពុករលួយបានធ្វើឲ្យប៉ះពាល់ដល់ដំណើរការលាតត្រដាងនូវការពិត ដែលភារកិច្ចនេះត្រូវបានប្រគល់ជូនចៅក្រមស៊ើបអង្កេត ហើយដែលចៅក្រមស៊ើបអង្កេតត្រូវទទួលភារកិច្ចដ៏ធំមួយនេះ។ ដំណើរការនេះមិនអាចកាត់ផ្តាច់ចេញពីស្ថាប័នតុលាការទេ ពីព្រោះវាត្រូវបានបំពេញក្នុងនាម និងនៅក្នុងរង្វង់ស្ថាប័នតុលាការ[23]។ ជារួម ក៏ដូចជាសេចក្តីសង្ខេបមកគណៈកម្មាធិការសិទ្ធិមនុស្ស " ដែលជាការធានាដាច់ខាតឲ្យដំណើរការស្វែងរកយុត្តិធម៌ប្រព្រឹត្តទៅដោយប្រក្រតីភាព (...) គឺមានលក្ខណៈចាំបាច់ក្នុងការការពារសិទ្ធិមនុស្សដ៏មានប្រសិទ្ធិភាព [24]"។

២៣. នេះជាមូលហេតុ ដែលថាការបង្គាប់ឲ្យមានការទាក់ទងគ្នាតាមរយៈឯកសារក្នុងគោលដៅដើម្បីបំភ្លឺលើករណីចោទប្រកាន់អំពីអំពើពុករលួយ ហើយដែលពុំមែនជាការបំពានលើអំណាចទេនោះ គឺជាកាតព្វកិច្ចរបស់សហចៅក្រមស៊ើបអង្កេត ។ សហចៅក្រមស៊ើបអង្កេតមានសមត្ថកិច្ច ហើយក៏មានមធ្យោបាយផងដែរ [25]។ ក្នុងគ្រប់ករណីទាំងអស់ ក្រមសីលធម៌តុលាការ[26] បើសិនជាមិនមែនកិត្តិយសទេនោះ និងតម្រូវឲ្យចៅក្រមស៊ើបអង្កេត ក្នុងនាមជាចៅក្រមត្រូវការពារស្ថាប័នតុលាការមួយនេះ។

២៤. ការនិយាយពីច្បាប់តែងតែតម្រូវឲ្យចៅក្រមជ្រើសរើសរវាងការបកស្រាយ និងទទួលស្គាល់ទំនួលខុសត្រូវទាំងស្រុងលើការនិយាយនេះ។ ក្នុងន័យនេះ ការយោងទៅលើការអនុវត្តច្បាប់យ៉ាងសាមញ្ញ

---

[23] ទាក់ទងចំណុចនេះ សូមពិនិត្យមើលការបកស្រាយនៅក្នុងសេចក្តីស្នើសុំបំពេញកិច្ចស៊ើបសួរលើកទី ១១ ក៏ដូចជាសារណាបណ្តឹងឧទ្ធរណ៍របស់ក្រុមមេធាវីការពារក្តីលោក នួន ជា ទាក់ទងដល់ចំណុចអស់ទាំងនេះ។

[24] កំណត់សម្គាល់ទូទៅលេខ ១៣ នៃគណៈកម្មាធិការសិទ្ធិមនុស្សចុះថ្ងៃទី ១៣ ខែ មេសា ឆ្នាំ ១៩៨៤។

[25] ស្របតាមវិធានទី ៥៥.៥ ខ) នៃវិធានផ្ទៃក្នុង សហចៅក្រមស៊ើបអង្កេតអាច "ស្នើសុំនូវពត៌មាន និង ជំនួយទៅគ្រប់បណ្តារដ្ឋទាំងអស់ ទៅអង្គការសហប្រជាជាតិ និងទៅគ្រប់បណ្តាអង្គការរដ្ឋាភិបាល និងមិនមែនរដ្ឋាភិបាល ឬក៏ទៅគ្រប់បណ្តាប្រភពដ៏ទៃទៀត ដែលខ្លួនគិតថាសមស្រប"

[26] មាត្រា ១.១ នៃក្រមសីលធម៌តុលាការបានតម្រូវឲ្យចៅក្រមនៃ អវតក ត្រូវការពារ "ឯករាជ្យក្នុងការងារនិងសិទ្ធិអំណាច របស់ខ្លួន និងប្រកាន់នូវជំហរនេះក្នុងការបំពេញតួនាទីជាមន្ត្រីតុលាការរបស់ខ្លួន "។

គឺតែងស្តែងចេញពីការគិតស្រមើស្រមៃទាំងអស់។ អ្នកខ្លះថែមទាំងបានចាត់ទុកថា ជា"ការលាក់ពុតមួយ (...) ដែលបង្ហាញឡើងដូចជាផ្អែកលើអំណាចដ៏ខ្ពង់ខ្ពស់មួយ ស្ថិតនៅខ្ពស់ផុតពីលើផលប្រយោជន៍ កាតព្វកិច្ច និងទុក្ខកង្វល់នានា" ...។ល។ ពីអ្នកដែលគាត់តែងវាឡើង ពីសំណើ ពីបទដ្ឋាននានា ដែលមួយផ្នែកអាស្រ័យទៅលើគោលជំហររបស់អ្នកដែលបានលើកពីបញ្ហានេះឡើងក្នុងវិស័យច្បាប់ "[27] ។

- **ការបដិសេធបំពេញមុខងារតុលាការ និងការប្រកែកផ្តល់ការកាត់ក្តី**

២៥. សេចក្តីសម្រេចរបស់សចសដែលមិនអនុវត្តសមត្ថកិច្ចរបស់ខ្លួននោះ ហើយដោយឧបាស្រ័យផ្សេងទៀតលែងអាចធ្វើបាន និង/ឬមិនមានប្រសិទ្ធិភាព[28] គឺជាការប្រកែកមិនព្រមកាត់ក្តីជាអចិន្ត្រៃយ៍ដែលជនត្រូវចោទទាំងអស់ រួមទាំងលោក ខៀវ សំផន កំពុងប្រឈមមុខនៅថ្ងៃនេះទៅវិញទេ។

២៦. តាមពិត ទាំងអស់នេះត្រូវបានព្រមព្រៀង " ពិតណាស់ សចសត្រូវធានាថា គ្រប់ចំណុចនៃនីតិវិធីដែលកំពុងដំណើរការក្នុងពេលបច្ចុប្បន្ននៅក្នុងអវតក មិនត្រូវបានគេគោរព *ជាពិសេស* ចំពោះរឿងដែលថា គ្រប់ទង្វើដែលជាការជ្រៀតជ្រែកចូលក្នុងកិច្ចការរដ្ឋបាលរបស់អង្គជំនុំជម្រះទាំងអស់ត្រូវបាន "ដាក់ទណ្ឌកម្ម ឬបញ្ជូនទៅអាជ្ញាធរមានសមត្ថកិច្ច"" (អក្សរទ្រេតត្រូវបានបន្ថែម)។ ដូច្នេះហេតុអ្វីក៏ពួកគេមិនធ្វើ?

២៧. ហេតុការណ៍ដែលអំពើពុករលួយមិនត្រូវបានរកឃើញជាស្ថាពរ ឬថា រដ្ឋទាំងឡាយត្រូវបានប្តឹងពីអំពើពុករលួយ មិនបង្កើតបានជាឧបសគ្គដល់ទង្វើរបស់សចសទេ វិធាន៣៥-២ នៃវិធានផ្ទៃក្នុងផ្តល់លទ្ធភាពឲ្យពួកគេយ៉ាងជាក់លាក់ក្នុងការបើកកិច្ចស៊ើបអង្កេត"ជាបន្ថែម" នៅពេលដែលពួកគេមាន "មូលហេតុដែលគួរឲ្យជឿបាន" ទង្វើដែលជាការជ្រៀតជ្រែកចូលក្នុងកិច្ចការរដ្ឋបាលរបស់អង្គជំនុំជម្រះ។ អត្ថបទច្បាប់មិនបានចែងអំពីផ្នែកណាមួយដែលត្រូវបានរក្សាទុកសម្រាប់រដ្ឋ និង/ឬ

---

[27] P. Bourdieu *"les juristes, gardiens de l'hypocrisie collective"* នៅក្នុងបទដ្ឋានគតិយុត្តិ និងនិយ័តកម្មសង្គម។ វណ្ណកម្ម LGDJ "នីតិនិងសង្គម" ១៩៩១។ មានបញ្ជាក់ក្នុង Chambon (P.), GUERY (C.), *Droit et pratique de l'instruction préparatoire.* Dalloz action 2007-2008, កថាខ័ណ្ឌ ១៣.៧៣ (បកប្រែក្រៅផ្លូវការ)។

[28] លើចំណុចនេះ សូមយោងទៅសំណើសុំបើកកិច្ចស៊ើបសួរទី១១ ដែលបានលម្អិតអំពីការខំប្រឹងប្រែងរបស់ក្រុមការពារក្តី ក្នុងការទាមទារសិទ្ធិរបស់ខ្លួន។

អង្គការសហប្រជាជាតិលើបញ្ហានេះឡើយ។ ផ្ទុយមកវិញ វាគឺជាផ្នែកមួយដែលស្ថិតក្នុងមុខងារតុលាការ។

២៨. ដូចគ្នាដែរ វាមិនសូវជាប់ទាក់ទងគ្នា ហើយក៏មិនទៀងត្រង់ ការដែលលើកអំពីហេតុការណ៍ដែលថា ក្រុមការពារក្តីគ្រាន់តែបានលើកឡើង "អំពីការប្រមើលមើលឃើញ អំពីផលវិបាកដ៏អាក្រក់ ជាយថាហេតុណាមួយ ប្រសិនបើមានអំពើពុករលួយគ្រប់រូបភាពកើតឡើង ចំពោះដំណើរការនៃនីតិវិធីតុលាការតែប៉ុណ្ណោះ"[29] ថា ជាការបង្ហាញមួយដើម្បីបដិសេធការចូលពិនិត្យមើលឯកសារភស្តុតាងសំខាន់ៗ...។ អំណះអំណាងនេះជាការព្រមព្រៀងយ៉ាងស្ងៀមស្ងាត់ជាបន្ថែមថា ទម្រង់នៃអំពើពុករលួយខ្លះមានលក្ខណៈមិនហួសហេតុ។ ម្យ៉ាង វាមិនមែនយ៉ាងដូច្នេះឡើយ ហើយម្យ៉ាងទៀតវាផ្ទុយនឹងសេចក្តីថ្លែងការណ៍របស់លោក LEMONDE របស់សហព្រះរាជអាជ្ញាអន្តរជាតិ[30] ចៅក្រមអន្តរជាតិ[31] ព្រមទាំងអង្គការក្រៅរដ្ឋាភិបាលនានា និងបណ្តាជនទាំងឡាយដែលត្រូវបានចោទសួរអំពីបញ្ហានេះ។

២៩. ប្រសិនបើការដែលនិយាយថា ក្រុមការពារក្តីពុំអាចបង្ហាញឱ្យឃើញថាមានហេតុការណ៍នៃអំពើពុករលួយជាការត្រឹមត្រូវ-ដែលនេះមិនមែនជាតួនាទីរបស់ក្រុមការពារក្តី ទោះក្នុងករណីណាក៏ដោយ-ក៏វាច្បាស់លាស់ដែលថាគ្មាននរណាម្នាក់អាចធានាបានថា អវតកត្រូវបានលើកលែងអំពីហេតុការ

---

[29] ដីកាសម្រេច កថាខណ្ឌ១២។

[30] តាមសហព្រះរាជអាជ្ញាអន្តរជាតិ គឺលោក Robert Petit ការចោទប្រកាន់ពីអំពើពុករលួយនៅអវតក "has to go away so it no longer shares the headlines with the more important work of the court. Half the headlines are about the problem they refuse to deal with, It threatens the continuation of the court. It's a very real problem.", (Susan Postlewait, "Khmer Rouge Trial Threatened", *Asia Sentinel,* ថ្ងៃទី២៤ មេសា ២០០៨។

[31] នៅក្នុងកិច្ចប្រជុំពេញអង្គ លើកទី៤របស់អវតក លោកស្រី Silvia Cartwright ចៅក្រមសាលាដំបូង បានប្រកាសថា ចៅក្រមអន្តរជាតិទំនងនឹងចាត់វិធានការណ៍គ្រប់យ៉ាងដើម្បីឱ្យ"ការចោទប្រកាន់ទាំងអស់នេះរលាយបាត់ទាំងស្រុង" មុននឹងបើកការកាត់ក្តី ដោយអះអាងថា ការកាត់ក្តី "មិនត្រូវប្រឡាក់ប្រឡូកដោយសារអំពើពុករលួយទេ"។ នៅក្នុងកិច្ចប្រជុំពេញអង្គកាលពីពេលថ្មីៗនេះ លោកស្រី Silvia Cartwright បានអះអាងដោយខ្លួនឯងក្នុងនាមចៅក្រមអន្តរជាតិទាំងឡាយ ដោយរលើកឡើងវិញថា ចៅក្រមអន្តរជាតិ "នឹងមិនអនុញ្ញាតឱ្យអំពើពុករលួយចូលមកក្នុងកាងារតុលាការ ក្នុងការផ្តល់យុត្តិធម៌ជូនប្រជាជនកម្ពុជាបានទេ" ដោយក្នុងនោះកំណត់ថា អំពើពុករលួយជា "បញ្ហាចម្បង"។ ហើយពួកគេលើកទឹកចិត្ត "គ្រប់ការខំប្រឹង ដើម្បីធ្វើយ៉ាងណាឱ្យការចោទប្រកាន់ទាំងនោះត្រូវបានដោះស្រាយយ៉ាងពេញទី (...) និងបណ្តឹងទាំងឡាយត្រូវបានដោះស្រាយប្រកបដោយតម្លាភាព។" (បកប្រែក្រៅផ្លូវការ) (Douglas Gillison, "ECCC Judges meet to Discuss Trial Procedures", The Cambodia Daily, 2 septembre 2008)

នេះបានដែរ។ លោក ស៊ាន វិសុទ្ធ ខ្លួនគាត់ផ្ទាល់បានថ្លែងថា "យើងមិនអាចនិយាយថា គ្មានអំពើពុករលួយសោះ" នៅអវតកបានទេ[32]។

៣០. ក្នុងករណីណាក៏ដោយ បើសិនជាមិនមានអំពើពុករលួយក៏ដោយ[33] ក៏ការចោទប្រកាន់ពីអំពើពុករលួយនេះបានធ្វើឲ្យខូចកិត្តិយសយ៉ាងច្រើនដល់អវតក ដែលបង្កបានជាមហន្តរាយដល់នីតិវិធី។ ចាប់តាំងពីខែសីហា ឆ្នាំ២០០៨មក កម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ (UNDP) ដែលគ្រប់គ្រងហិរញ្ញវត្ថុរបស់ប្រទេសម្ចាស់ជំនួយសម្រាប់ផ្នែកជាតិនៅអវតក បានផ្អាករាល់ការផ្ទេរប្រាក់ទៅដល់ផ្នែកជាតិនៅតុលាការ ដរាបណាបទចោទពីអំពើពុករលួយទាំងនេះមិនទាន់ត្រូវបានដោះស្រាយ[34]។

៣១. ជាទីបញ្ចប់ ផ្ទុយមកវិញ ការខ្វះការប្រុងប្រយ័ត្នរបស់រដ្ឋាភិបាលកម្ពុជា និងអង្គការសហប្រជាជាតិក្នុងការធានាអំពីតម្លាភាពលើអំពើពុករលួយនេះ[35] បានបញ្ជាក់ឲ្យឃើញថា សហចៅក្រមស៊ើប

[32] Leslie Hook, "Cambodia's Flawed Search for Justice", *Far Eastern Economic Review*, ខែមករា កុម្ភៈ ២០០៨ ទំព័រ៣៩ (បកប្រែក្រៅផ្លូវការ)

[33] ផ្ទុយមកវិញ លើចំណុចនេះ យើងសង្កេតឃើញថា សំណើសុំបើកកិច្ចស៊ើបសួរលើកទី១១បានលើកឡើងយ៉ាងច្បាស់លាស់អំពីលទ្ធផលដែលបណ្តាលមកពីអំពើពុករលួយនេះ។

[34] តាមលោក Jo Scheuer នាយកកម្មវិធីអភិវឌ្ឍសហប្រជាជាតិ (UNDP) ប្រចាំកម្ពុជា៖ "ដូចដែលយើងបានប្រាប់ទៅរដ្ឋាភិបាល និងដៃគូរបស់យើង និងដូចដែលយើងបានឲ្យដឹងដល់សារព័ត៌មានជាច្រើនដង អំពីជំហររបស់យើង ពោលគឺរក្សាសេចក្តីសម្រេចរបស់យើងមិនដាក់ឲ្យដំណើរការមូលនិធិ គឺនៅតែមិនផ្លាស់ប្តូរ តាំងពីហិរញ្ញវត្ថុត្រូវបានព្យួរទុកពីលើកដំបូង នាខែកក្កដាមកម្ល៉េះ។ ក្នុងនាមជាអ្នកគ្រប់គ្រងមូលនិធិ កម្មវិធីអភិវឌ្ឍសហប្រជាជាតិ (UNDP) ជាអ្នកទទួលខុសត្រូវលើមូលនិធិទាំងនេះ ហើយមានកាតព្វកិច្ចធានាថា មូលនិធិទាំងនេះត្រូវបានប្រើប្រាស់ដើម្បីសម្រេចតាមកម្មវត្ថុដែលបានកំណត់។ យើងនៅតែបន្តថា យើងត្រូវការសង្កេតថា ការចោទប្រកាន់ទាំងឡាយត្រូវបានបំបាត់ ហើយដាក់ឲ្យដំណើរការនូវយន្តការផ្សេងៗ ដើម្បីការពារមូលនិធិ ដើម្បីនឹងអាចផ្ទេរបានទៀត" សារផ្ញើរមកអង្គភាពគាំពារការការពារក្តី ថ្ងៃទី២៩ មេសា ២០០៩។ យើងកត់សម្គាល់ឃើញថា សេចក្តីសម្រេចកាលពីពេលថ្មីៗនេះរបស់ប្រទេសជប៉ុន ក្នុងការផ្តល់ប្រាក់ចំនួន ៤ ១៧០ ៨១៤ ដុល្លា នៅនាទីចុងក្រោយ និងតាមសំណើសុំរបស់រដ្ឋាភិបាលកម្ពុជា សម្រាប់ឧបត្ថម្ភដល់តុលាការខាងផ្នែកកម្ពុជា ត្រូវបានធ្វើឡើងដោយពុំមានរូបិយបដិភោគរបស់កម្មវិធីអភិវឌ្ឍសហប្រជាជាតិ (UNDP)ឡើយ។

[35] យោងតាមកាសែត *Phnom Penh Post* ថ្ងៃទី៩ មេសា ២០០៩ (បកប្រែក្រៅផ្លូវការ)៖ បីថ្ងៃបន្ទាប់ពីកិច្ចចរចារអង្គការសហប្រជាជាតិ និងរដ្ឋាភិបាល មិនបានសម្រេចព្រមព្រៀងណាមួយលើវិធានការណ៍ប្រឆាំងនឹងអំពើពុករលួយនៅអវតកឡើយ។ នេះជាការព្យាយាមលើកចុងក្រោយ។ តាមអ្នកតំណាងអបជ លោក Taksoe-Jensen អបជមិនចង់បន្តការពិភាក្សាលើបញ្ហានេះទេ។ លោកឧបនាយករដ្ឋមន្ត្រី សុខ អាន បានបដិសេធផ្តល់ការអត្ថាធិប្បាយ។ ចំពោះអង្គការក្រៅរដ្ឋាភិបាល ឈ្មោះអង្គការសង្គមយុត្តិធម៌បើកចំហ (Open Society Justice Initiative) "ភាពស្ងាត់ស្ងៀមរបស់រដ្ឋាភិបាលក្នុងបង្កើតឲ្យមានយន្តការដែលឲ្យជឿទុកចិត្តបាន ដើម្បីបង្កា ឬដោះស្រាយពីអំពើពុករលួយ គឺជាការរំលោភលើកិច្ចព្រមព្រៀងស្តីពីអវតក ក្នុងនោះ

00323315



អង្គេតគួរយកតាមគោលការណ៍នៃការបំពេញបន្ថែម ដែលអនុវត្តនៅតុលាការអន្តរជាតិទាំងឡាយ និងបើកកិច្ចស៊ើបសួររដ្ឋបាលមួយដោយដោយឯករាជ្យ។

៣២. ជាសរុបមក និងដោយពិចារណាលើភាពមិនអាចប្រព្រឹត្តទៅបានជាដាច់ខាតសម្រាប់រកយុត្តិធម៌ក្នុង "បរិយាកាសពុករលួយ"[36] សហមេធាវីការពារក្តីយល់ឃើញថា សចសមានសមត្ថកិច្ច និងកាតព្វកិច្ចក្នុងការធ្វើ។ គឺសិទ្ធិទទួលបានការកាត់ក្តីប្រកបដោយយុត្តិធម៌ របស់លោក ខៀវ សំផន ដែលចោទជាបញ្ហា ហើយសិទ្ធនេះមិនអាចតថ្លៃបានទេ!

## អាស្រ័យហេតុនេះ

៣៣. សហមេធាវីការពារក្តីសូមដល់អង្គបុរេជំនុំជម្រះ មេត្តា**បដិសេធ**ដីកាសម្រេចរបស់សចស និង**កាត់សេចក្តីលើបញ្ហានេះ** ដើម្បីបំពេញតាមពាក្យសុំក្នុងកថាខណ្ឌ២២ នៃ "សំណើសុំបើកកិច្ចស៊ើបសួរលើកទី១១" និងដើម្បីធានាដល់សិទ្ធិរបស់លោក ខៀវ សំផន ក្នុងការទទួលបានការកាត់ក្តីប្រកបដោយយុត្តិធម៌ផងចុះ ។

៣៤. ដូចគ្នាដែរ ក្រុមការពារក្តីសូមទទូចឲ្យមាន**សវនាការជាសាធារណៈមួយ** ជាបន្ទាន់ដើម្បីស្តាប់អំណះអំណាងរបស់បណ្តាភាគីដើមបណ្តឹងឧទ្ធរណ៍ទាំងអស់លើបណ្តឹងឧទ្ធរណ៍នេះ។

ជំនួសសហមេធាវីការពារក្តី

លោកមេធាវី ស សុវ៉ាន

---

តុលាការត្រូវតែអាចគួរឲ្យជឿទុកចិត្តបាន ហើយត្រូវគោរពតាមបទដ្ឋានអន្តរជាតិ" (សូមមើល សុខខេង "Tribunal graft talks fail to find a solution" *Phnom Penh Post,* 9 avril 2009 ថ្ងៃទី៩ មេសា ២០០៩។

[36] "The Court on Trial", The Economist ថ្ងៃទី២ មេសា ២០០៩។